00195289

**Declassified to Public**
**06 September 2012**

ឯកសារ A 99/II

# ជូនចំពោះ

## លោក យូ ប៊ុនឡេង និង លោក Marcel Lemonde

## សហចៅក្រមស៊ើបអង្កេត

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 06 / 2008
ម៉ោង (Time/Heure): 10:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

*សំណុំរឿង ស៊ើបអង្កេត លេខ : ០០១/១៨-០៧-២០០៧-ECCC/OCIJ*

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 09 / JUNE / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.FRY

<u>កម្មវត្ថុ</u> : ពាក្យសុំអនុញ្ញាតឲ្យលោក **François Bizot** ជួបលោក កាំង ហ្គេកអ៊ាវ

ជូនចំពោះលោកសហចៅក្រមជាទីគោរព

យើងខ្ញុំ ការ សាវុត្ថ និង **François Roux** ជាមេធាវីឲ្យលោក កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ក្រោយពីបានដឹងថាលោក **François Bizot** បានដាក់ពាក្យសុំដើម្បីអនុញ្ញាតឲ្យជួបលោក កាំង តាមលិខិតចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៨ ហើយក្រោយពីបានដឹងថា លោកសហចៅក្រមមិនបានផ្តល់ចម្លើយជាវិជ្ជមានទេ តាមរយៈលិខិតនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨ យើងខ្ញុំសូមជម្រាបជូនលោកសហចៅក្រមមេត្តាជ្រាបថា សហមេធាវីស្នើសុំឲ្យលោកពិនិត្យពាក្យសុំនេះឡើងវិញ។

សូមរំលឹកថា ប្រសិនបើលោក **François Bizot** នឹងផ្តល់សក្ខីកម្ម នៅពេលសវនាការជំនុំជម្រះក្តី គាត់នឹងផ្តល់សក្ខីកម្មទាក់ទងនឹងបុគ្គលិកលក្ខណៈរបស់លោក កាំង ហ្គេកអ៊ាវ ហើយមិនមែនទាក់ទងនឹងអង្គហេតុទេ ។ មកទល់ពេលនេះ ទស្សនៈរបស់លោក **François Bizot** ទាក់ទងទៅនឹង

បុគ្គលិកលក្ខណៈរបស់លោក កាំង ហ្កេកអ៊ាវ ច្បាស់លាស់ហើយ ។ ម្យ៉ាងទៀត ទស្សនៈនេះ ក៏ត្រូវបានលាតត្រដាងជាសាធារណៈផងដែរ ។

លោក François Bizot បានផ្តល់សក្ខីកម្មអំពីបុគ្គលិកលក្ខណៈរបស់លោក កាំង នៅក្នុងសៀវភៅនិពន្ធរបស់គាត់ ក្រោមចំណងជើងថា "Le portail" (ខ្លោងទ្វារ) -គាត់ធ្លាប់បានធ្វើការអត្ថាធិប្បាយទៅលើសៀវភៅនេះ នៅក្នុងអំឡុងពេលកិច្ចពិភាក្សាដេញដោលដោយលោកចៅក្រម Lemonde តាំងពីថ្ងៃទី២២ ខែមករា ឆ្នាំ ២០០៨ (D ៤០) - ហើយគាត់ក៏បានផ្តល់សក្ខីកម្មអំពីបុគ្គលិកលក្ខណៈរបស់លោក កាំង ក្នុងឱកាសនៃបទសម្ភាសន៍ជាច្រើន ដែលបានចុះផ្សាយនៅក្នុងសារព័ត៌មាន (ឧទាហរណ៍ ក្នុងកាសែត "Libération" ចុះថ្ងៃទី១០-១១ ខែឧសភា ឆ្នាំ ២០០៨) ។ ម្យ៉ាងទៀត គាត់បានផ្តល់សក្ខីកម្មអំពីបុគ្គលិកលក្ខណៈរបស់លោក កាំង ផងដែរនៅក្នុងភាពយន្ត "Derrière le portail" (ក្រោយខ្លោងទ្វារ) ដែលត្រូវបានថតដោយលោក Jean Baronnet (ឆ្នាំ២០០៤) ។

ដោយហេតុនេះ ជំនួបរវាងគាត់និងលោក កាំង ពិតជាគ្មានឥទ្ធិពលទៅលើកិច្ចពិភាក្សាដេញដោលនៅចំពោះមុខចៅក្រមនៃសាលាដំបូងនោះទេ ។ លោក Bizot នឹងមានឋានៈដូច លោកប៉ាស្ទ័រ (លោកគ្រូគង្វាល) Lapel ដែលអាចទៅជួបជាមួយកូនក្តីរបស់យើងខ្ញុំបាន (ប៉ុន្តែ វាជាការសោកស្តាយដោយគាត់មិនមែនជាអ្នកនៅក្នុងប្រទេសកម្ពុជានោះទេ)

ហើយដែលគាត់គ្រាន់តែជាសក្សីបញ្ជាក់ពីសីលធម៌ប៉ុណ្ណោះ ។

យើងខ្ញុំសូមសង្កត់ធ្ងន់ ដូចអ្នកជំនាញលោកស្រី Sironi បានកត់សម្គាល់ដែរថា ជំនួបនិងការពិភាក្សាដូចនេះ មានសារៈសំខាន់ណាស់ ទាំងផ្នែកខាងទឹកចិត្ត ទាំងផ្នែកខាងផ្លូវចិត្ត ចំពោះការគិតគូរផ្ទាល់ខ្លួន-

00195291

ឯកសារ A ១១/II

របស់លោក កាំង ឆ្ពោះទៅរកការទទួលស្គាល់នៃការទទួលខុសត្រូវ ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះចម្លើយជាវិជ្ជមាន ដែលលោកអាចផ្តល់ ហើយសូមលោកសហចៅក្រមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០០៨

សម្រាប់សហមេធាវីទាំងពីររូប

មេធាវីម្នាក់ក្នុងចំណោមមេធាវីទាំងពីររូប

លោក ការ សាវុត្ថ